# ការសម្ភាសន៍របស់ម៉ាកយាយឈ្មោះ អែនលី

កៈ អ្នកដែលបានសម្ភាសន៍ រត្ន ស្រីភាព  ខៈ អ្នកដែលបានគេនឹងសម្ភាសន៍ អែនលី

**ជីវប្រវត្តិសង្ខេបរបសអ្នកមីងឈ្មោះអែន លី**

កៈ ជាដំបូងនាងខ្ញុំសុំជំរាប់សួរអ្នកមីងហើយនាងខ្ញុំនឹងឈ្មោះរត្ន ស្រីភាព អនុញ្ញាតសម្ភាសជីវប្រវិត្តរបស់ ម៉ាកយាយនៅពេលដែលខ្ញុំនឹងបានធ្វើការសម្ភាសកាលនឹងធ្វើឡើងដោយសាលាមួយដែលមានឈ្មោះថាសាលារៀនមួយដែលនៅអាមេរិចណាម៉ាកយាយឡើងដើម្បីថែរក្សាជីវប្រវត្តិរបស់ម៉ាកយាយដើម្បីថែរក្សាជីវប្រវត្តិដូងតារបស់ម៉ាកយាយជាការចង់ក្រងនៅខ្សែរជីវិតមួយសំរាប់ទុកអោយកូនចៅជំនាន់ក្រោយអោយគេនឹងបានដឹងថាអោយអ្នកជំនាន់មុនគេនឹងបានរស់នៅដោយរបៀបណាតស៊ូរដោយរបៀបណានៅក្នុងជីវិតរបស់ពួកគេហើយជាសិសេរផ្លូវកាត់នៅសម័យនីសង្គមអីខ្លះនៅក្នុងជិវិតចឹងណាម៉ាកយាយចងនៅពេលដែលខ្ញុំនឹងបានធ្វើការសម្ភាសនឹងធ្វើនៅថ្ងៃ២៨ខែ០៨ឆ្នាំ២០១៨។

កៈ ចឹងម៉ាកយាយមានឈ្មោះអីដែលម៉ាកយាយ?

ខៈ  អីខ្ញុំនឹងមានឈ្មោះ អែន លី។

កៈ នឹងឈ្មោះម៉ាកយាយពេលក្នុងសៀវភៅគ្រួសារពេលម៉ាកយាយ?

ខៈ  នៅក្នុងសៀវភៅគ្រួសារនឹងតែម្ដង។

កៈ ចាំចឹងលោកយាយដែលមានឈ្មោះខាងក្រៅទេលោកយាយ?

ខៈ
អូឈ្មោះខ្ញុំនឹងនៅខាងក្រៅនឹងមានឈ្មោះនឹងបានច្រើនណាស់អូមានគេនឹងបានហៅខ្ញុំយាយឈូងហើយនឹង។

កៈ ចឹងគេនឹងបានហៅយាយស្បៅហើយនឹងយាយឈូងទៀតលោកយាយ?

ខ៖ ចាំនឹងហើយកាលនឹងផ្ទះខ្ញុំនឹងបានព្រក់ដំបូងស្បៅ។

ក៖ អីចាំលោកយាយ?

ខ៖

កាលនឹងពីមុនមកនឹងខ្ញុំនឹងបានដាំឈូងក្នុងបឹងហើយឥឡូវនឹងគេនឹងបានលុបបឹងនឹងអស់ហើយគេនឹងបានប្រកើតរោងចក្រហើយ។

ក៖ ចឹងម៉ាកយាយសព្វថ្ងៃនឹងអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំនឹងមានអាយុនឹង៦០ឆ្នាំហើយ។

ក៖ ចឹងម៉ាកយាយមានបានចាំថ្ងៃកំណើតរបស់ខ្លួន
ទេថាម៉ាកយាយនឹងបានកើតមនៅថ្ងៃណាហើយនឹងហើយណាចឹង?

ខ៖ អូអើយអត់បានចាំទេដឹងថាខ្ញុំនឹងបានឆ្នាំជូនតែខ្ញុំនឹងបានដឹងថាថ្ងៃខែអត់ដឹង។

ក៖ ចឹងម៉ាកយាយនឹងបានដឹងថ្ងៃនឹងទីប៉ុន្មានដែលម៉ាកយាយ?

ខ៖ អូថ្ងៃនឹងខ្ញុំដឹងថាថ្ងៃស្រុកទីនឹងខ្ញុំនឹងអត់បានដឹង។

ក៖ ចាំចឹងបានដឹងថានៅថ្ងៃស្រុកនឹងហើយនៅឆ្នាំជូន?

ខ៖ ហើយចុះកើតម៉ារជំនាន់នឹងយើងនឹងបានដឹងអីជំនាន់ពីដើមមកដឹងខែយើងខ្មែរនឹង។

ក៖ ជំនាន់អាពតនឹង?

ខ៖ មិនមែនជំនាន់អាពតនឹងទេ។

ក៖ ចឹងម៉ាកយាយនឹងបានកើតនៅមុនជំនាន់អាពតនឹងទៀតចឹងម៉ាកយាយ?

ខ៖ មុនអាពតនឹងទៀតមកមុននឹងជំនាន់លុននល។

ក៖

មុនលុននលនឹងជំនាន់សម្តេចតានៅជំនាន់ព្រៃម៉ាគឺចឹងនៅពេលដែលម៉ាកយាយនឹងបានកើតនឹងនៅជំនាន់មុននឹងសម្តេចតា?

ខ៖  ចាំ!

ក៖
ចឹងម៉ាកយាយនៅជំនាន់នឹងតើម៉ាកយាយកាលនឹងបានមុំានអាយុនឹងបានប្រាំហើយនឹងប្រាំមួយឆ្នាំហើយកាលនឹងម៉ាកយាយនៅជំនាន់នឹងនៅសប្បាយនៅឡើយនឹងកាលនឹងម៉ាកយាយ?

ខ៖  នៅសប្បាយតើម៉ារជំនាន់នឹងកាលមុននឹង។

ក៖
ចាំចឹងជំនាន់ដែលនៅជំនាន់នឹងសម្តេចតានឹងបានគ្រប់គ្រងចឹងកាលនឹងសប្បាយម៉ាកយាយកាលនឹង?

ខ៖
កាលនឹងសម្តេចតាជំនាន់នឹងបានព្រៀមក្រណាត់អីនឹងបានអោយកាលនឹងតាមទំលាក់ពីលើយន្តហោះមកនាំគ្នានឹងបានរត់។

ក៖
ចាំនឹងហើយកាលនឹងសម្តេចតាគាត់នឹងបានចែកអោយប្រជាជនចឹងកាលនឹងម៉ាក់យាយ?

ខ៖
នឹងហើយកាលនឹងគាត់នឹងបានទំលាក់ពីឡើយយន្តហោះគាត់នឹងបានទំលាក់មកចឹងនាំគ្នានឹងបានរត់ទៅរើស។

ក៖ ចឹងកាលនឹងសប្បាយទេម៉ាកយាយកាលនឹង?

ខ៖
សប្បាយដែលតើតាមវាលស្រែហើយដល់ទៅកាលនឹងនៅក្មេងៗកាលនឹងស្លៀកសំពត់នឹងតែត្រឹមៗកាលនឹង។

ក៖ ចឹងជំនាន់នឹងកាលនឹងគេនឹងមិនបាននៅស្លៀកក្បឹងទេកាលនឹងម៉ាកយាយ?

ខ៖ អូកាលនឹងមិនបានទាន់នឹងបានស្លៀមក្បឹងទេកាលនេងនៅក្មេងៗនឹងយើងនឹងស្លៀកសំពត់កាលនឹងនៅក្មេងៗកាលនឹងមិនបានទាន់ធំពេញវ័យអីកាលនឹង។

ក៖ ដល់ពេលេនឹងបានពេញវ័យកាលនឹងគេនឹងបានស្លៀកក្បឹងចឹងកាលនឹង?

ខ៖  ចាំនឹងហើយ។

ក៖ ចាំចឹងជំនាន់នឹងដូចជាម៉ាកយាយនឹងបាននៅសប្បាយដែលក្នុងរយះពេលប្រាំពីរហើយនឹងប្រាំបីឆ្នាំនឹងចឹងកាលនឹងម៉ាកយាយ?

ខ៖ ម៉ារជំនាន់នឹងបានសប្បាយដែលប៉ុន្តែកាលនឹងម៉ារពេលៗទេកាលនឹងពីព្រោះយើងពេលថ្ងៃនឹងយើងទៅដល់ស្វនដល់ពេលល្ងាចយើងនឹងបានដក់ចឹងទៅពេលព្រឹកឡើងស្វូន។

ក៖ ចាំ!

ខ៖  នឹងកាលនឹងពេញអើយប្រាំបីហើយនឹងប្រាំបួនឆ្នាំនឹងកាលនឹង។

ក៖ ចាំ!

ខ៖ កាលនឹងខ្ញុំនឹងបានដក់ស្វូនហើយកាលនឹងលែងមើលប្អូនហើយកាលនឹងខ្ញុំនឹងហើយខ្ញុំនឹងបានមើលប្អូនខ្ញុំនឹងបានតែម៉ារពេលៗកាលនឹងដល់ចឹងទៅកាលនឹងខ្ញុំមើលដឹងនឹងបានឆ្លៀតពេលឪកាលនោះកាលនឹងដល់ពេលចឹងទៅមើលដឹងក្របីអោយទៅស៊ីស្មៅចឹងទៅ?

ក៖ ចាំចឹងតើម៉ាកយាយមានទៅកន្លែងកើតនៅណាដែលកាលនឹង?

ខ៖ ខ្ញុំនឹងបានកើតនៅស្រុកព្រៃវែងកាលនឹងកាលពីមុននឹងខ្ញុំនឹងបានកើតនៅស្រុកព្រៃវែងខេត្តព្រៃវែងកាលមុននឹងកាលនឹងឃុំទឹកថ្លាភូមិទួលអំពិលនឹងកាលនឹង។

ក៖
ចាំចឹងជាមូលហេតុអីបានជាម៉ាកយាយនឹងបានផ្លាក់មករស់នៅទីក្រុមភ្នំពេលនឹងកាលនឹង
ម៉ាកយាយ?

ខ៖
ចុះកាលនឹងវានឹងបានអត់ពេកចឹងទៅកាលនឹងចុះមេឃកាលនឹងវានឹងបានរាំងកាលនឹង
ហើយកាលណាមេឃនឹងបានវានឹងបានរាំងខ្ញុំនឹងបានមករស់ស៊ីនៅទីក្រុមចឹងកាលនឹងដ
ល់ចឹងទៅកាលនឹងខ្ញុំនឹងបានដើរបេះផ្លែឈឺចឹងទៅកាលនឹងហើយនឹងបានបេះស្លឹកឈឺទៅ
អាស្លឹកឈឺជាបន្លែចឹងទៅកាលនឹងបេះផ្កាអីចឹងទៅកាលនឹងលក់កាលនឹង។

ក៖ ចឹងកាលនឹងម៉ាកយាយបានមករស់នៅនឹងបានប៉ុន្មានឆ្នាំហើយកាលនឹង?

ខ៖ ខ្ញុំនឹងបានមករស់នៅទីនឹងតាំងពីចិតហើយកាលនឹង។

ក៖ តាំងពីបែកអាពតហើយកាលនឹង?

ខ៖ មើលតាំងពីបែកអាពតហើយនឹងតាំងពីឆ្នាំចិតប្រាំបួនហើយនឹងកៅគត់កាលនឹង។

ក៖
ចឹងនៅឆ្នាំកៅគត់នឹងម៉ាកយាយកាលនឹងបានមករស់នៅទីក្រុងភ្នំពេញនឹងកាលនឹងហើយ
ម៉ាកយាយកាលនឹងពីដំបូងកាលនឹងមករស់នៅណាដែលកាលនឹងឬមួយក៏បានចាប់ទៅ
ដៅមកម៉ាកយាយនឹងបានមករស់នៅនឹងតែម្តងកាលនឹង?

ខ៖
ខ្ញុំនឹងបានមករស់នៅនឹងតែម្តងអូអត់ទេកាលនឹងមុននឹងខ្ញុំនឹងបានមករស់នៅផ្លូវថ្មល់រទេះ
ភ្លើងកាលនឹង។

ក៖ ចាំ!

ខ៖
ដល់កាលនឹងផ្លូវនឹងវាបានចង់អៀតគ្នាពេកកាលនឹងមីងខ្ញុំនឹងក៏បានចែកដីកាលនឹងអោយ
ខ្ញុំនឹងបានជុំនៅនឹងកាលនឹង។

ក៖ ចឹងដីនឹងជាកម្មសិ្ទតផ្ទាល់របស់អ្នកមីងកាលនឹង?

ខ៖  ចាំនឹងហើយដីនឹងដីខ្ញុំតែគ្រន់តែខ្ញុំនឹងបានអត់ផ្ទះនឹងនៅគេ។

ក៖ ចាំតែទិចនឹងមានលុយនឹងបានធ្វើផ្ទះហើយ?

ខ៖  ដឹងកាលណានឹងបានមានលុយនឹងបានផ្ទះនឹងគេទេអើយ។

ក៖ ខំព្រឹងទៅនឹងបានផ្ទះនឹងបានរស់នឹងគេហើយម៉ាកយាយ?

ខ៖
រកកាន់តែខ្លាងកូនខ្ញុំនឹងបានធំនឹងក៏កាន់តែធំខ្លាងដែលចឹងខ្ញុំនឹងហើយណាចោយនឹងក៏កាន់តែខ្លាងណាថៅកំព្រានឹងដល់ទៅពីរនាក់ទៀតហើយនៅរៀនទៀតមិនបានមានអ្នកណានឹងបានរក។

ក៖ ចឹងបានធ្វើអោយម៉ាកយាយនឹងបានពិបាកខ្លាងនៅក្នុងគ្រួសារចឹងនែ៎ម៉ាកយាយ?

ខ៖  អឺ!នឹងហើយ។

ក៖ ចឹងភូមិនឹងគេនឹងបានហៅភូមិអីដែលម៉ាកយាយ?

ខ៖  ភូមិនឹងគេនឹងបានហៅភូមិបឹងស្រលាង ខណ្ឌឫស្សីកែវ សង្កាត់ឫស្សីកែវ។

ក៖ ចឹងនឹង ភូមិស្រលាង សង្កាត់ឫស្សីកែវ  ឃុំឫស្សីកែវ រាជធានីភ្នំពេញចឹងម៉ាកយាយ?

ខ៖  នឹងហើយរាជធានីភ្នំពេញ។

ក៖ ចាំចឹងម៉ាកយាយមានបងប្អូនបង្កើតផ្ទាល់នឹងប៉ុន្មាន់នាក់ដែលម៉ាយាយ?

ខ៖  ខ្ញុំនឹងមានបងប្អូនខ្ញុំនឹងប្រាំបួននាក់។

ក៖ ចឹងម៉ាកយាយនឹងមានបងប្អូនម៉ាកយាយនឹងដល់ទៅប្រាំបួកនាក់?

ខ៖
ពឹងគេនឹងបានរស់នៅតែស្រែនឹងទេគេនឹងមិនដែលនឹងបានមកនៅពេញនឹងខ្ញុំហើយនឹងប្អូនខ្ញុំនឹងមួយនឹងហើយឥឡូវនឹងលក់ដីភូមិនៅពេញនឹងបានទៅរស់នៅជនបទវិញ។

ក៖ ចឹងគាត់នឹងបានរស់នៅជនបទវិញចឹងកាលនឹងម៉ាកយាយ
ចឹងម៉ាកយាយមានបងប្អូនម៉ាកយាយដល់ទៅប្រាំបួកនាក់នឹងតើម៉ាកយាយជាកូនទីប៉ុន្មាន

ដែលម៉ាកយាយហើយបងប្អូនម៉ាកយាយនឹងតើមានប្រុសនឹងប៉ុន្មាននាក់ហើយស្រីនឹងមានប៉ុន្មាននាក់ដែលម៉ាកយាយ?

ខ៖ ខ្ញុំនឹងជាកូនទៅមួយ។

ក៖ ចាំ

ខ៖ ប្រុសបី!

ក៖
ប្រុសបីហើយស្រីនឹងប្រាំមួយចាំចឹងទាំងអស់នឹងមានដល់ទៅប្រាំបូននាក់ចឹងម៉ាកយាយជាកូនទៅមួយកត្តាកិច្ចជាកូនទីមួយនឹងបានទទួលខុសត្រូវបីបាច់ចិញ្ចឹមកូនៗបន្តពីលោកឪពុកហើយនឹងម្តាយច្រើនខ្លាងមែនទែង?

ខ៖ នឹងហើយខ្ញុំនឹងបានច្រើន។

ក៖
ម៉ាយាយអាចដំណើររឿងដែលម៉ាកយាយបានគ្រប់គ្រង់បងប្អូនម៉ាកយាយកាលនឹងបានធ្វើអីខ្លះកាលនឹង?

ខ៖
ខ្ញុំកាលពីដើមមកខ្ញុំនឹងមិនបានធ្វើអីទេអ្វើតែស្រែនឹងកាលនឹងហើយនឹងបានដក់ស្ទូននឹងហើយរួចពីនឹងទៅខ្ញុំនឹងបានឆ្លៀតពេលឪកាលចឹងទៅខ្ញុំនឹងបានមើលគោមើលក្របីចឹងទៅមើលគោមើលក្របីចឹងទៅមានពេលនឹងខ្ញុំនឹងបានដើរបេះប៉ោកបន្លែពីវាលមកស្លរដាំទៅ។

ក៖
ចាងកាលនឹងម៉ាកយាយបានបេះមកចឹងបានស្លរដាំចឹងទៅកាលនឹងចាំដោយសារតែម៉ាកយាយបានប្រើជីវិតជាអ្នកជនបទដូចជាគ្រឿងសំម្លរមួយពេលដែលយើងនឹងបានត្រូវស្លរនឹងគឺយើនឹងបានដើរបេះចឹងទៅកាលនឹងហើយមិនបានដូចជានៅទីក្រុងភ្នំពេញយើងនឹងត្រូវតែទិញអីទាំងអស់ចឹងកាលនឹងចាំចឹងម៉ាកយាយដែលបានចាំសាច់រឿងអ្វីខ្លះដែលបានរស់នៅតាំងពីក្មេងជាមួយនឹងបងប្អូនម៉ាកយាយកាលនឹងចូលចិត្តបានធ្វើកាងារអីជាមួយនឹងគ្នាទេដូចជាកាណែរនាំកាងារណាហើយនឹងបានដាក់ផែងការណាដើម្បីអោយយើងនឹងបានធ្វើការ?

ខ៖
ម៉ែឪខ្ញុំនឹងបានដាក់ផែងការនឹងកាលនឹងមានដាក់អីអោយតែបានស្ទូនដក់នឹងហើយនឹងបានបង្រៀនចឹងទៅហើយកាលនឹងខ្ញុំនឹងមិនបានធ្វើអោយម៉ែឪឃ្មុំនឹងបានហាត់នឹងខ្ញុំទេកាលនឹងយើងនឹងបានដឹងពេលវេលាយើងដល់ពេលល្ងាចចឹងទៅយើងដក់ឡើងពីស្ទូនចឹងមកម៉ោង១១ដល់ម៉ោង២
ហើយនឹងម៉ោង៣យើងនឹងដក់ដល់ម៉ោង៥អីនឹងយើងនឹងបានងើបឡើងមកហើយកាលនឹងដល់ចឹងទៅយើងនឹងបានហាន់បន្លែហើយនឹងបានបេះបន្លែដូចជាកញ្ចែតយកវាមកពីវាលចឹងទៅហាន់បាយជ្រូកហើយនឹងឬក៏បបរហើយនឹងបានបុកលាយកន្ទួកដាក់អោយជ្រូកចឹងទៅចិញ្ចឹមជ្រូកហើយនឹងបានបញ្ចូលគោប៉ោកស្មៅហើយនឹងដាក់ចំបើអោយគោនឹងបានស៊ីទៅកាលនឹងហើយនឹងបានបន់ពូកភ្លើងចឹងទៅហើយក៏មកបានចូលដេកទៅភ្ញាក់មកពីម៉ោងបួនឬមួយក៏ម៉ោងប្រាំចឹងទៅក៏បានភ្ញាក់ឡើងមកដាំបាយចឹងទៅស្ទូន។

ក៖
ចាំតើនៅពេលនេះតើពួកគាតើនឹងបានរស់នៅណាដែលហើយនឹងបានរស់នៅកន្លែងណាខ្លះទៅម៉ាកយាយ?

ខ៖ បងប្អូនខ្ញុំនឹងបានរស់នៅតែភូមិនឹងតែមួយនឹង។

ក៖ ចាំចឹងនៅខាងព្រៃវែងនឹង?

ខ៖
ចាំនឹងហើយនៅខាងព្រៃវែងនឹងតែកុំថាវានឹងបានរស់នៅភូមិត្រួយអំពិលនេងតែទាល់តែថាផ្ទះវានឹងតឡូវនឹងគេនឹងបានមានគ្រួសារអាស់ហើយផ្ទះគេនឹងបានរស់នៅជាប់ៗគ្នាចឹងផ្ទះនឹងៗចឹងស្នឹតតែផ្ទះបងប្អូនចឹងទៅបី បួន ប្រាំ ប្រាំមួយនាកើចឹងទៅ។

ក៖
ប៉ុន្តែកាលនឹងបងប្អូនម៉ាកយាយនឹងគេនឹងបានរស់នៅជិតគ្នាចឹងទៅប៉ុន្តែផ្ទះបងប្អូនម៉ាកយាយនឹងជិតគ្នា?

ខ៖
ចំានឹងហើយផ្ទះនឹងបានរស់នៅជិតគ្នាប៉ុន្តែវានឹងបានខុសភូមិនឹងគ្នាហើយនឹងបានមួយប្លង់ៗជិតគ្នាចឹងចែកអោយបានមួយប្លង់នៅជិតគ្នា។

កៈ
ចាំចឹងចំពោះលោកឪពុកហើយនឹងអ្នកម្ដាយរបស់ម៉ាកយាយតើម៉ាកយាយដែលបានចាំឈ្មោះពួកគាត់ទេម៉ាកយាយ?

ខៈ ចាំតើ!

កៈ ចាំចឹងគាត់នឹងបានមានឈ្មោះអីគេម៉ាកយាយ?

ខៈ ម៉ែខ្ញុំនឹងមានឈ្មោះ សេង លឹម ឪខ្ញុំនឹងមានឈ្មោះ អែម ចាន់។

កៈ
ចឹងតើលោកឪពុកហើយនឹងអ្នកម្ដាយម៉ាកយាយនឹងណាដូចជាសព្វថ្ងៃនឹងរស់នៅឬក៏គាត់នឹងបានស្លាប់ហើយលោកម៉ាកយាយ?

ខៈ គាត់នឹងបានស្លាប់បាត់អស់ហើយ។

កៈ
នៅពេលដែលលោកឪពុកហើយនឹងអ្នកម្ដាយរបស់ម៉ាកយាយនឹងតើកាលនឹងគាត់នឹងមានអាយុប៉ុន្មានដែលម៉ាកយាយ?

ខៈ
ម្ដាយខ្ញុំនឹងគាត់នឹងបានស្លាប់នៅចឹតគត់ដល់អាយុចឹតគត់នឹងបានគាត់នឹងបានស្លាប់ហើយឪពុកខ្ញុំអាយុប៉ែតបីកាលនឹង។

កៈ ចឹងគាត់នឹងបានស្លាប់នៅអាយុប៉ែតសិបបានគាត់នឹងបានស្លាប់ចឹងម៉ាកយាយ?

ខៈ អូអត់ទេគាត់នឹងបានស្លាប់នឹងនៅអាយុនឹងប៉ែតបីកាលនឹងគាត់នឹងបានស្លាប់។

កៈ
ចាំចឹងតើលោកទាំងពីរនឹងតើគាត់នឹងបានកើតនៅខែណាឆ្នាំណាដែលម៉ាកយាយហើយសំរាប់ម៉ាកយាយមានបានចាំទេដូចជាឆ្នាំខ្មែរដូចជា ជូន ខោល ថោះ
អីនឹងចាំពួកគាត់នឹងឆ្នាំណាទេ?

ខៈ កាលនឹងម៉ែខ្ញុំនឹងបានដឹងគាត់នឹងបានឆ្នាំ ឆ្នាំរោងតែឪខ្ញុំនឹងគាត់នឹងឆ្នាំកោ។

ក៖
ចឹងគាត់នឹងមានឆ្នាំនឹងឆ្នាំកោចឹងតើម៉ាកយាយមានបានដឹងថាគាត់បានកើតនៅកន្លែងណាខ្លះទេដូចជាគាតើនឹងបានកើតនៅស្រុកព្រៃវែងនឹងតែម្តងហើយឬក៏គាត់នឹងបានកើតនៅណាដែលកាលនឹង?

ខ៖
ចំណែកម៉ែខ្ញុំនឹងគាត់នឹងបានតើកនៅភូមិទូលអំពិលនឹងតែម្តងហើយគាត់នឹងជាអ្នកដែលបានរស់នៅខេត្តព្រៃវែងនឹងតែមួយនឹងទេហើយចំណែកឪខ្ញុំគាតើនឹងបានរស់នៅភូមិទ្រូនប៉ុន្តែភូមិនឹងមានឈ្មោះថាភូមិទ្រូននៅភូមិទឹកថ្លាតែមួយនឹងទេ។

ក៖ ចឹងភូមិនឹងបាននៅក្នុងខេត្តព្រៃវែងជាមួយនឹងគ្នាម៉ាកយាយ?

ខ៖
នឹងហើយគាត់នឹងបានរស់នៅស្រុកភូមិព្រៃវែងជាមួយនឹងគ្នាហើយគាត់នឹងបានខុសភូមិ។

ក៖ ចឹងកាលនឹងគ្រាន់បានដឹងថាភូមិឡើងហើយនឹងភូមិក្រោមចឹងម៉ាកយាយ?

ខ៖ នឹងហើយ!

ក៖
ចឹងចំពោះម៉ាកយាយផ្ទាល់នៅដែលមានបានចាំថាលោកឪពុកអ្នកម្តាយរបស់ម៉ាកយាយកាលពីគាតើនឹងបាននៅរស់ចឹងតើគាតើនឹងបានប្រកបមុនរកបរអីកាលនឹងមកចិញ្ចឹមមាកយាយហើយនឹងបងប្អូនម៉ាកយាយកាលនឹង?

ខ៖
មិនបានមានអីក្រៅពីធ្វើស្រែទេពៅអើយនៅនឹងគាត់នឹងតែបានធ្វើតែស្រែនឹងកាលនឹងអត់ដែលដេឡគាត់នឹងមិនបានដែលអីកាលនឹងជួញដែលពីមុនមកគាតើនឹងបានធ្វើជួញត្រីគាត់នឹងបានរកត្រីនឹងបានលក់កាលពីយើងកាលពូមុនមកត្រីកាលនឹងវានឹងបានសំបូរត្រីគាត់នឹងបានដាក់ធ្វើអីអីឆ្លាក់មិញកាលនឹងគាត់នឹងបានចេះឆ្លាក់តាមទូលតាមវាស្រែ។

ក៖
ចាំចឹងកាលនឹងគាត់នឹងបានចេះលើទ្រនុបនឹងចេះទប់កុំអោយត្រីនឹងបានហូរចេញចឹងកាលនឹង?

ខ៖
នឹងហើយកាលនឹងគាត់នឹងបានចេះធ្វើទប់ចឹងកាលនឹងកុំអោយត្រីនឹងហូរចេញចឹងកាលនឹងធ្លាក់អានឹងបានត្រីកាលនឹងបានទៅលក់ចឹងដែលកាលនឹងមានតែពេងនេងហើយមិនបានមានអីទៀតទេហើយប់ក្រៅពីនឹងមានតែស្រែទេកាលនឹងគាត់នឹងមិនបានដែលនឹងរកអីផងកាលនឹង។

ក៖
ចា៎ចឹងតើម៉ាកយាយគិតយ៉ាងដូចម្ដេចដែលចំពោះលោកឪពុកហើយនឹងអ្នកម្ដាយរបស់យាយថាពួកគាត់នឹងជាមនុស្សបែកណាដែល?

ខ៖ មិច!

ក៖
តើម៉ាកយាយបានគិតដូចម្ដេចដែលចំពោះលោកឪពុកហើយនឹងអ្នកម្ដាយរបស់ម៉ាកយាយនឹងណាថាគាត់នឹងជាមនុស្សបែកណាគាត់នឹងបានស្លូតបូតឬក៏គាត់នឹងមិចដែល?

ខ៖
អូលោកឪពុកខ្ញុំកាលនឹងគាត់នឹងបានស្លូតណាស់ដែលបានស្គាល់បានវ៉ៃងកូនហើយនឹងបានវ៉ៃងថៅណាទេហើយមនតែបានដឹងនាំកូនអោយបានរកស៊ីខ្ញុំតាំងពីតូចក្រូចឆ្មាមកមិដែលហើយម៉ែឪខ្ញុំគួលខ្ញុំនឹងបានមួយរំពាតមិនដែលទេហើយខ្ញុំនឹងបាននិយាយអោយបានរួមទៅខ្ញុំនឹងបានវ៉ៃកូនគាត់នឹងបានមួយទេគាត់នឹងបានស្លូតណាស់។

ក៖
ហើយខ្ញុំនឹងបានជឿថាចាស់ទុំពីសង្គមណាពួកគាត់ជាមនុស្សទទួលការខុសត្រូវចិញ្ចឹមកូនគាត់ណាស់កាលនឹង?

ខ៖
ចិញ្ចឹមគាត់ហើយកាលនឹងគាត់នឹងបានធ្វើស្រែកាលនឹងធ្វើតែស្រែទេកាលនឹងហើយគាត់នឹងមិនបានធ្វើអីផ្សេងទេកាលនឹង?

ក៖
នឹងហើយទូលគាត់នឹងបាននឿងហាត់យ៉ាងណាក៏ដោយក៏គាត់នឹងបាននៅស៊ូទ្រាំនឹងបានចិញ្ចឹមកូនគាត់នឹងអោយបានធំធាត់នឹងបានល្អចឹងកាលនឹងម៉ាកយាយប៉ុន្តែក្នុងកាលដែល

បានអោយបីបាច់រៀនសូត្រអីពីសង្គមនឹងយើងនឹងមិនបានទាន់មានកាលជាក់លាក់នោះទេ?

ខ៖ កាលនឹងរៀននឹងក៏មិនបានអស់ប៉ុន្មានទេកាលនឹងលុយកាលនឹងក៏យើងនឹងបានទៅរៀនមុនដំបូងកាលនឹងខ្ញុំនឹងបានរៀនជាមួយនឹងលោកកាលនឹងលោកនឹងបានបង្រៀនកាលនឹងអស់ពីនឹងទៅខ្ញុំនឹងបានមករៀនជាមួយនឹងគ្រូនឹងខ្មែរ។

ក៖ ចឹងកាលនឹងម៉ាកយាយនឹងបានមករៀននឹងគ្រូខ្មែរវិញកាលនឹង?

ខ៖ ជាមួយនឹងព្រះសក់ចឹងកាលនឹងមុននឹងលោកកាលនឹងតែកាលនឹងគាត់នឹងខ្មែរដូចគ្នានឹងកាលនឹង។

ក៖ ចាំពីមុននឹងលោកអស់ពីលោកគ្រូខ្មែរ?

ខ៖ ជាមួយនឹងព្រះសក់កាលនឹង?

ក៖ ចឹងបានជាខ្ញុំនឹងបានដឹងថាម៉ាកយាយនឹងបានទៅរៀនជាមួយនឹងលោកគ្រូមុនអាគមចឹងកាលនឹងម៉ាកយាយ?

ខ៖ លោកគ្រូលោកកាលនឹងគាត់នឹងបានបង្រៀនចឹងកាលនឹងដល់ចឹងទៅខ្ញុំនឹងបានរៀននឹងផុតពីលោកចឹងទៅខ្ញុំនឹងបានទៅរៀនជាមួយនឹងព្រះសក់។

ក៖ ចឹងម៉ាកយាយនឹងបានរៀននឹងជាមួយនឹងលោកកាលនឹងមុនហើយក្រោមមកម៉ាកយាយនឹងបានរៀនជាមួយនឹងលោកគ្រូហើយនឹងអ្នកគ្រូវិញចឹងម៉ាកយាយ?

ខ៖ ចាំនឹងហើយខ្ញុំនឹងបានមករៀនជាមួយនឹងលោកគ្រូហើយនឹងអ្នកគ្រូវិញកាលនឹងឈប់រៀនជាមួននឹងលោកហើយកាលនឹង។

កៈ
ចឹងកាលនឹងម៉ាកយាយដែលបានចាំសាច់រឿងអីខ្លះជាមួយនឹងគាត់ហើយនឹងលោកឪពុកហើយនឹងអ្នកម្ដាយទេកាលនឹងដែលម៉ាកយាយនឹងបានរស់នៅជាមួយនឹងគាត់ចឹងកាលនឹងមានភាពជូតជត់អីខ្លះជាមួយនឹងលោកឪពុកហើយនឹង្នកម្ដាយកាលនឹងជាមួយនឹងកូនៗចឹងកាលនឹង?

ខៈ
កាលដែលបានរស់នៅជាមួយនឹងឪពុកហើយនឹងម្ដាយកាលនឹងយើងនឹងចេះតែមានភាពជូនជត់ខ្លួអហើយកាលនឹងកាលដែលយើងនឹងបានធ្វើស្រែកាលនឹងច្រូតអីហើយចឹងទៅកាលនឹងពេលប្រាំងចឹងកាលនឹងធ្វើនំបាញ់ចុកដើរទូលលក់តាមផ្ទះគេចឹងកាលនឹងចឹងធ្វើនំបាញ់ចុកធ្វើនំអាកោរចឹងទៅកាលនឹងលក់ដូចជាដើរលក់ម្លូរស្លាចឹងទៅដើរលក់តាមផ្ទះចឹងទៅកាលនឹងហើយខ្សែរជីវិតរកស៊ីតែពឹងនឹងចឹងទៅកាលនឹង។

កៈ
ដោយសារពួកយើងនឹងបានដើររេកស៊ីចឹងទៅកាលនឹងទក់ៗតាមនឹងទៅកាលនឹងតាមលទ្ធភាពចឹងទៅកាលនឹង?

ខៈ
នឹងហើយកាលនឹងយើងនឹងបានចេះតែរកស៊ីចឹងទៅកាលនឹងហើយកាលនឹងខ្ញុំនឹងមិនបានទាន់មានគ្រួសារទេកាលនឹងខ្ញុំនឹងរកស៊ីចឹងទៅអើយបានភ្ញាក់ពីយប់ចឹងទៅកាលនឹងធ្វើម្សៅស្ករចឹងទៅកាលនឹងបុកហើយនឹងបានទូលលក់ចឹងទៅកាលនឹងម៉ែខ្ញុំនឹងគាត់នឹងមិនបានស្រួយខ្លួនចឹងទៅកាលនឹងខ្ញុំនឹងបានដើរទូលលក់ចឹងទៅកាលនឹងខ្ញុំនឹងជាមួយនឹងបងប្អូនខ្ញុំកាលនឹងបានដើរលក់ចឹងទៅកាលនឹងហើលខ្ញុំនឹងបានដូរនំបាញ់ចុកមួយផ្ទូលហើយចឹងទៅស្រូវនឹងបានបួនផ្ទូលមក។

កៈ ចាំ!

ខៈ ចឹងទៅអាកោរនឹងម៉ារគីឡូមកចឹងទៅស្រូវនឹងម៉ារតាំពឹងនេះមក។

កៈ អីអោយតែធ្វើមិញនឹងអោយតែបានលុយចឹងមកកាលនឹង?

ខ៖
ធ្វើមិញអោយតែបានលយុអោយតែបានអង្គរនឹងបានធ្វើមកចឹងកាលនឹងចិញ្ចឹមប្អូនខ្ញុំកាលនឹង។

ក៖ តែកាលនឹងគេនឹងបានចោយកាសចឹងម៉ាកយាយជំនាន់នឹង?

ខ៖ នឹងហើយកាលនឹងដូរជាស្រែកាលនឹងហើយនឹងមានកាសដែលនឹង។

ក៖ ចាំយើងនឹងមិនមែនដូចឥឡូវនឹងយើងនឹងបានចោយបី បួន
ប្រាំរយហើយនឹងមួយពាន់ទេយើងកាលនឹងបួន
ប្រាំរយកាលនឹងយើងនឹងបានធំខ្លាងណាស់កាលនឹងមិនបានមានលទ្ធភាពនឹងបានដល់ទេកាលនឹង?

ខ៖ អូនឹងហើយប់កាលនឹងយើងនឹងមានលយុដល់ទៅបួន
ប្រាំរយនឹងបានធ្វើផ្ទះគ្បឿងបានបួនប្រាំខ្នងកាលនឹងបាននៅនឹងហើយកាលនឹងបានតែប្រាំរយនឹងកាលនឹងតែគេនឹងបានច្រើនតែចោយអង្គរចឹងកាលនឹងហើយនឹងបានយកស្រូវកាលនឹង។

ក៖
ចាំនឹងហើយកាលនឹងគេនឹងបានចោយមាសហើយនេងអង្គរចឹងកាលនឹងហើយនឹងបានដូរយកសំពត់ហូលហើយនឹងផាមួនចឹងកាលនឹង?

ខ៖
នឹងហើយកាលនឹងគេនឹងបានចោយមាសហើយនឹងអង្គរអូកាលម៉ារជំនាន់បែកចិតប្រាំកាលនឹងអឺស្រូវហើយនឹងអង្គរដូរបានសំពត់ចឹងកាលនឹងបានស្លៀកតើសំពត់ហូលគេ។

ក៖ អ្នកខ្លះកាលនឹងមកចឹងបានដូរយកមាសទៀតកាលនឹង?

ខ៖ នឹងហើយ!

ក៖
ម៉ាក់ខ្ញុំកាលនឹងដូរម៉ាក់ខ្ញុំបានដាត់ពីអាពតមកចឹងកាលនឹងគាត់នឹងបានដើរមកផ្ទះវិញចឹងកាលនឹងគេបានជំលៀកទៅដល់ខាងខេត្តកំពុងស្ពឺចាំដល់ពេលចឹងកាលនឹងម៉ាក់ខ្ញុំនឹងបានជាអ្នកកំពុងចាមហើយដល់ពេលគាត់នឹងបានដាច់ពីកំពុងចាមដូចជាតាខ្ញុំនឹងបានឃើញដើ

មខ្មោចចឹងទៅតាខ្ញុំនឹងបានកាត់អោយម្តាយខ្ញុំនឹងបានរ៉ែកមកចឹងកាលនឹងតាខ្ញុំនឹងគាត់នឹងបានធ្វើរ៉ែងមួយខាងនឹងពីរកាលម៉ាក់ខ្ញុំគាត់បានរ៉ែងមកចឹងគេនឹងបានសុំតាខ្ញុំនឹងដូលយកខ្សែដៃនឹងខ្សែកដូលយកខ្នាយចឹងកាលនឹងតែម៉ែខ្ញុំកាលនឹងគាត់អត់ស្ទូវឆ្លាត់កាលនឹងគាត់កាលនឹងគាត់ខ្លាចអត់អីប្អូនគាត់ញ៉ាំអីចឹងកាលនឹងគាត់នឹងអត់ហានដូរទេចឹងជំនាន់ដាច់ពីជំនាន់ពី៧៩សម័យសង្គ្រាមមុននឹងដែលលោកយាយបាននិយាយជាមួយនឹងខ្ញុំនឹងជំនាន់នឹងគេបានចាយលុយកាក់ចឹងកាលនឹងដូរយកអង្ករហើយនឹងបានដូរយកលុយកាក់ចឹងកាលនឹង?

ខ៖  នឹងហើយកាលនឹងគេនឹងបានដូរយ្យូរសំពតចឹងកាលនឹង។

ក៖
សែនជាងហើយនឹងកៅចឹងហើយការនឹងចឹងតើម៉ាក់យាយដែលបានដឹងពីរសាច់រឿងដែលបានទាក់ទងជាមួយនឹងលោកឪពុកហើយនឹងអ្នកម្តាយដែលទេកាលពីរគាត់នឹងរស់នៅពីរក្មេងចឹងម៉ាក់យាយដែលបានដឹងទេកាលពីក្មេងៗដែលមានភាពកំសត់ខ្លះទេ?

ខ៖
គាត់ដូរមិនដែលបានធ្លាប់មិនដែលនិយាយអិផងនឹងចុងបញ្ចប់គាត់នឹងបានតែប្រដៅកូនគាត់អើយខ្ញុំព្រឹងធ្វើស្រែនឹងអោយបានធ្វើភ្លឺហើយនឹងមើលគោហើយនឹងមើលក្របីចាប់មាន់ទាពីនឹងចូលទ្រុងពេលប្រលុបឡើងចឹងទៅ។

ក៖
ចាំ!ចុះម៉ាក់យាយដែលបានកើតទាន់លោកតាហើយនឹងលោកយាយខាងលោកៀពុកហើយនឹងអ្នកម្តាយដែលឬទេ?

ខ៖  អត់ទាន់ទេ។

ក៖
ចឹងកាលនឹងដែលបានកើតទាន់ហើយបានដឹងអីពីលោកឪពុកហើយនឹងអ្នកម្តាយដែលទេដែលគាត់នឹងដែលនិយាយអំពីរឿងគាត់ដែលរឺទេ?

ខ៖
កាលនឹងខ្ញុំនឹងបានដឹងឈ្មោះខ្លះដែលតែគ្រាន់តែដំណើរដូចអត់ដែលបានរឺស្ទូវនិយាយថាមិចនៅរឺមួយគាត់នឹងដែលនិយាយដែលឬក៏ខ្ញុំនឹងមិនបានចាំ។

ក៖ ចាំ!

ខ៖
ចុះកាលនឹងមកដល់ឥឡូវនឹងហើយពេលសូម្បីតែខ្ញុំនឹងបាននិយាយនឹងអោយគេបានដូកទឹកទៅជាដូកបាយចឹងកាលនឹងដាក់កែវអីណា។

ក៖
ចាំ!ចឹងម៉ាក់យាយមានដែលបានចាំឈ្មោះលោកតាហើយនឹងលោកយាយនៅពេលលោកយាយបានធ្វើស៊ាក់ការបូជាគាត់នឹងបានធ្វើនៅថ្ងៃសីលដូចជាបានហៅឈ្មោះគាត់?

ខ៖ ខ្ញុំនឹងបានធ្វើអោយគាត់ហើយនឹងចាំឈ្មោះគាត់តើ។

ក៖ ហើយតើគាត់នឹងមានឈ្មោះអីដែលម៉ាក់យាយ?

ខ៖ ដូចជាយាយខ្ញុំនឹងមានឈ្មោះថាយាយ ព៉ាច ហើយតាខ្ញុំនឹងឈ្មោះ តា សេង។

ក៖ នឹងខាងអ្នកម្ដាយ?

ខ៖
ចាំ!នឹងខាងម៉ែហើយខាងប៉ាខ្ញុំនឹងខ្ញុំនឹងបានប្រើនឹងខាងត្រកូលតាអើយតាអែននឹងខ្ញុំនឹងតាគោ។

ក៖
ចឹងខាងលោកឪពុកនៅពេលដែលម៉ាក់យាយដែលបានចង់ចាំសេចក្ដីរឿងពេលដែលលោកយាយហើយនឹងលោកតាមានឈ្មោះអីនឹងពេលដែលម៉ាក់យាយដែលស៊ាក់ការបូជាគាត់រាល់ថ្ងៃសីលអីចឹងណាតែងតែបានអុនធូហើយដល់ដូនតាយើងអីចឹងដែលមានឈ្មោះនេះអីចឹងដែលជាសាច់ញ្ញាតិរបស់ម៉ាក់យាយហើយខ្ញុំនឹងបានដាក់ឡើងម៉ាក់យាយដែលបានធ្វើស៊ាក់ការបូជាលោកយាយនឹងបានដឹងថាមានឈ្មោះអីចឹងកាលនឹងលោកយាយ?

ខ៖ ចាំ!នឹងហើយខ្ញុំនឹងស្គាល់ដែល។

ក៖
ចាំ!ចឹងអោយលោកយាយបានដឹងចឹងលោកយាយប៉ុន្តែលោកយាយនឹងអត់បានដឹងសាច់រឿងអីជាមួយនឹងលោកតាហើយនឹងលោកយាយទេ?

ខ៖

អត់បានដឹងទេដូចគាត់នឹងបាននិយាយដែលតែខ្ញុំនឹងអត់វាអត់បានចាំខ្ញុំនឹងបានភ្លេចបានភ្លាំងអស់ទៅកាលនឹង។

ក៖

ចាំ!ចឹងចំពោះក្រុមគ្រួសារផ្សេងតើពួកគាត់ទាំងអស់គ្នាដែលបានរស់នៅខេត្តព្រៃវែនតាំងពីតូចរហូតដល់ធំម៉ាក់យាយ?

ខ៖

នឹងហើយកាលនឹងនាំគ្នានឹងរស់នៅខេត្តព្រៃវែងកាលនឹងតាំងពីតូចដល់ធំទលតែឥឡូវនឹងតែម្ដង។

ក៖

ចាំ!តាមកាលខ្ញុំនឹងបានគិតទៅតាំងពីជំនាន់តាទួចហើយនឹងយាយទួចមកម្លះលោកយាយ?

ខ៖ នឹងហើយ។

ក៖

ម៉ាក់យាយដែលមានបងប្អូនណាដែលនៅក្រៅប្រទេសដូចជាត្រឹមថៃហើយនឹងវៀតណាមទេអាមេរិចហើយនឹងកាណាដាទេ?

ខ៖

អូរអត់មានអូនអើយអត់មានទេពៅអើយពៅៗមិនខ្ញុំនឹងមាននឹងគេនឹងខ្ញុំនឹងប្រហែល(ទេ)តៅរកគេសុំគេនឹងយកលុយចោយខ្លះហើយមើលទៅ។

ក៖

ចុះលោកយាយមានកូនក្មួយសម័យនឹងធ្វើការទៅពលករទៅប្រទេសកូរ៉េអីខ្លះទេលោកយាយ?

ខ៖ អត់!

ក៖

ចាំ!ទាក់ទងនឹងស្វាមីអាពាហ៍ពិពាហ៍ម៉ាក់យាយផ្ទាល់តែម្ដងតើស្វាមីរបស់ម៉ាក់យាយនឹងគាត់មានឈ្មោះងីដែលម៉ាក់យាយ?

ខ៖  ឈ្មោះពេជ្រ តាឈ្មោះ ប៊ុន តាឪខងប្តីនឹងណា។

ក៖  ចឹងតាប៊ុនពេជ្រ?

ខ៖  ចាំប្តី ប៊ុនពេជ្រហើយចំណោតឪឈ្មោះ ខុន ។

ក៖
ចាំហើយម៉ាក់យាយមានដែលបានចាំថាកាលនឹងរៀនការជាមួយនឹងគាត់នឹងតាំងពីរឆ្នាំណាមក?

ខ៖  រៀបការនឹងតាំងពី៧៥កាលនឹងបែកអាពតហើយ។

ក៖  អើយនៅពេលតាំងពីរៀបការ៧៥នឹងដាច់អាពតបែកអាពត៧៩តើបានបែកអាពត?

ខ៖  អែនអើយកាលនឹងតរៀបការមុនអាពតតាំងពីអេតាំងបីរដំណើរប៉ុន្មានទេ។

ក៖  ចាំ!

ខ៖  អត់ចាំ!តាំងពីមុនបែកអាពតមក។

ក៖  កូនច្បងម៉ាក់យាយនឹងយាយនឹងមានអាយុប៉ុន្មានឆ្នាំហើយសព្វថ្ងៃនឹង?

ខ៖  កូនច្បងខ្ញុំប្រហែលអាយុ៥០ជាងហើយឯង។

ក៖  ៥០ចឹងរៀបការនឹងនៅមុនអាពតទៀត?

ខ៖  មុនអាពត។

ក៖
បើមើលម៉ាក់យាយការនឹងនៅមុនអាពតឆ្នាំ១៩៧៥នៅក្នុងសម័យអាពតវានឹងបានគ្រប់គ្រងយើងនឹងផ្ទាល់តែម្តង?

ខ៖  ចាំ!

ក៖  ចឹងម៉ាក់យាយបានរៀបការនឹងមុនអាពត?

ខ៖  មុនអាពតៗការម៉ារជំនាន់អាពតខ្ញុំនឹងបានកូនខ្ញុំនឹងមួយហើយ។

កៈ
ចាំចឹងម៉ាក់យាយបានរៀបការមុនអាពតនែ៎ដូចជាប៉ុន្មានដូចជាក្នុងអាពតនឹងកូនច្បងរបស់ម៉ាក់យាយបានប៉ុន្មានបានចូលអាពត?

ខៈ  កូនច្បងខ្ញុំនឹងបានប៉ុន្មានចូលអាពតអីខ្ញុំនឹងកំពងពោះធំ។

កៈ  កំពុងតែពោះធំចឹងមានន័យថាម៉ាក់យាយនឹងរៀបការនៅក្នុងឆ្នាំ១៩៧៦ឆ្នាំ?

ខៈ  ចាំ!

កៈ
ចឹងម៉ាក់យាយបានរៀបការនៅឆ្នាំ១៩៧៦នឹងគឺម៉ាក់យាយអ្នកក្នុងការជីវិត្តនឹងស្វាមីភរិយាជាមួយនឹងគ្នាហើយ?

ខៈ  ចាំ!

កៈ
តើអាពាហ៍ពិពាហ៍របស់ម៉ាក់យាយរៀបចំឡើងដោយឪពុកម្ដាយឬក៏នរណាជាអ្នករៀបចំអោយ?

ខៈ  ឪពុកម្ដាយជាអ្នករៀបចំអោយ។

កៈ  ការនឹងលោកតាមានជូនថ្លៃទឹកដើអោយបានប៉ុន្មានទេកាលនឹង?

ខៈ  ការម៉ាជំនាន់នឹងគ្មានអីថ្លៃទឹកដោះទេគ្រាន់តែថាគាត់អោយគោក្របីមួយ។

កៈ  គាត់បានអោយក្របីមួយការគាត់អោយរស់ឬក៏គាត់ក្របីមួយនឹងការតែម្ដង?

ខៈ  គាត់អោយនឹងរស់តែគាត់ក្របីនឹងការតែម្ដង។

កៈ  គាត់ក្របីនឹងតែម្ដង?

ខៈ
ក្របីមួយនឹងការតែម្ដងមានអីទេម៉ារជំនាន់នោះគេនឹងបានមុតលុយកាក់អស់ហើយយើងនឹងបានលុយណា។

កៈ ចឹងម៉ាក់យាយបានការនឹងបានក្របីមួយដែលសំរាប់ការនឹង?

ខៈ រួចម៉ារម្ហូបការ។

កៈ
ធ្វើម្ហូបការម៉ាក់យាយនឹងជាមូលហេតុអីបានជាម៉ាក់យាយជួបជាមួយនឹងគាត់ដូចជាម៉ាក់យាយស្គាល់គាត់ពីរកន្លែងណាមួយឬក៏គាត់?

ខៈ ការនឹងស្គាល់ម៉ាជំនាន់ចាស់ៗ។

កៈ ចាំ!

ខៈ គាត់នឹងបានរៀបចំអោយចឹងទៅ។

កៈ ចាំម៉ាក់យាយធ្លាប់រៀនភាសាខ្មែរបានខ្លះទេកន្លងមក?

ខៈ
អើយអកៈកម្មឥឡូវនឹងសរសោរលេងចេញហើយឯងអើយឥឡូវនឹងកុំថាអក្សពិននេះហើយទៅថានឹង។

កៈ ចាំ!ម៉ាក់យាយមើលដូចជាលក្ខណៈថាមើលដូចថាម៉ាក់យាយនឹងប្រើប្រាស់អត់កើត?

ខៈ
គ្រាន់តែខ្ញុំនឹងបានប្រើបានទិចទួចនឹងហើយគ្រាន់មើលដាច់នឹងទិចទួចវាមិនបានចេះជ្រៅជ្រោះ។

កៈ ចាំចឹងចំពោះម៉ាក់យាយថ្នាក់អកៈកម្មនឹងគេថាថ្នាក់ទី១២អកៈកម្មនឹងទេ?

ខៈ នឹងថ្នាក់ទី១២នឹងពីដើមនឹងថ្នាក់ ក ខ បែកផង។

កៈ ចាំ!

ខៈ ពិននឹង។

ក៖
ចឹងអើយតើម៉ាក់យាយអាចប្រាប់ខ្ញុំបានទេថាម៉ាក់យាយអាចចេះប្រើភាសាបរទេសអីខ្លះទេពីមុននឹងដូចថាបារាំងចូលមកចឹងកាលនឹងខ្លះអីចឹងតើម៉ាក់យាយបានចេះភាសាបារាំងទេ?

ខ៖
អត់អីទេអើយចេះដូចថាម៉ារជំនាន់អិនតាក់ចូលមកដល់ចូលទៅនឹងគេនឹងនៅតែតាមឃុំអីចឹងទៅណា។

ក៖ ចាំ!

ខ៖ អិនតាក់ចូលមកចឹងទៅយើងនឹងតែភូមិហើយភាសាអីនឹងយើងនឹងមិនបានចេះទេ។

ក៖
ចាំ!ៗហើយម៉ាក់យាយសូមប្រាប់ខ្ញុំពីខ្សែជីវិត្តរបស់ម៉ាក់យាយអោយខ្ញុំបានទិចបានទេពីកន្លងដាច់ពីអាពតមកចឹងណាតើម៉ាក់យាយធ្លាប់បានស៊ីឈ្នួលអោយគេទេកន្លងមក?

ខ៖
អូរម៉ាជំនាន់បានបែកអាពតមកមានតែស៊ីឈ្នួលដើរដក់អាវឈូកអោយគេដក់អោយគេ។

ក៖ ចាំ!

ខ៖ ដើរលក់អោយគេ។

ក៖ ចាំ!ដោយសារ?

ខ៖ បានអង្ករនឹងម៉ារគឺឡូរយកមកគ្រាន់តែចិញ្ចឹមកូនចឹងទៅបាន២ពាន៥រយ។

ក៖ ចាំ!

ខ៖
ទិញអង្ករផងទិញម្ហូបផងអត់មួយក៏មានមួយពេលកូននឹងឈឺទៅឆ្លៀតអាអង្ករពីរគឺឡូរនឹងទិញតែម៉ារឡូរទុកអាម៉ារឡូនឹងលក់ចោលយកលុយនឹងមកទិញថ្នាំពេទ្យនឹងអោយកូន។

ក៖ ចាំនឹងជីវិត្តរបស់ម៉ាក់យាយនឹងមានការកំសត់កំក្ររខ្លាំងមែនទេន?

ខ៖ អឺមិនដែលស្គាល់អង្គុញចឹងទេថ្ងៃនឹងទៅដើរបេះចាំមើលស្លឹកប៉ោះផងស្លឹកចុ៊នផេតផងប៉េះអាវ៉ែមអាត្រគួននឹងផងហើយដើរបួតត្រួនអំពិលតាមផ្លូវនឹងការបុនផ្លូវនឹងថ្នលទេភ្លើងអត់ទាន់មានផ្ទះអីចឹងៗទេកាលមុនណាកាលនឹងមានដើមឈើដើមព្រៃវានឹងបានដុះបួតត្រួនអំពិលត្រួនអីនឹងត្រគួនចុ៊នផេតអីនឹងកាលនឹងអីចឹងកាលនឹង។

ក៖ ចា៎!

ខ៖ ពិននឹងខ្ញុំនឹងដើរបេះទៅ។

ក៖ ចា៎ចឹងតើម៉ាក់យាយមានការផ្លាស់ប្ដូរតាំងពីជីវិត្តតាំងពីរតូចរហូតដល់ធំតើជីវិត្តរបស់ម៉ាក់យាយនឹងឬក៏អត់មានការផ្លាស់ប្ដូរអីគេឬក៏នៅតែមិនរហូត?

ខ៖ ខ្ញុំនឹងនៅតែពិបាករហូតមកដល់សព្វថ្ងៃនឹងរាល់ថ្ងៃនឹងក៏នៅនោះដីរោងចក្រគេន់សុំអាដីគេនឹងមើលនោះអារបងដែលធំលងតែម៉ារទិចនឹងបងនៃរបងមើលគេពីនឹងសុខចិត្តដាក់ជណ្ដើទៅដាំក្រលុងក្រលៀងនឹងស្រលេះនឹងដាំៗ។

ក៖ ចា៎ធ្វើមិចអោយតែបានអីលក់ចឹងទៅណា?

ខ៖ ធ្វើមិចអោយតែបានបេះលក់បានរួចសាហុយកូនរៀនផងគិតពីរនឹងមកខ្ញុំនឹងវេលាកូនណាទេកូនកំព្រាទៅណាបាត់ពីរនាក់។

ក៖ ចា៎!

ខ៖ និយាយទៅម្ដាយនឹងបានស្លាប់នឹងទើបតែបានអាយុនឹងបីឆ្នាំទេនឹងណាម្ដាយនឹងស្លាប់។

ក៖ ស្លាប់នឹងកូនម៉ាក់យាយបង្កើតនឹងកូន?

ខ៖
កូនខ្ញុំនឹងបង្កើតខ្ញុំនឹងខ្ញុំនឹងដើរមើលគ្រប់ពេទ្យគ្រប់គ្រូខ្មែរអស់ហើយមើលក៏មើលមិនបានជាទេ។

ក៖ ចាំគាត់នឹងបានស្លាប់ដោយសារជំងឺអីគេដែលកាលនឹងម៉ាក់យាយ?

ខ៖
ស្លាប់ពីរមុនដំបូងគេនឹងថាទឹកប្រៃហើយងស់ពីរទឹកនោមប្រៃមកពេទ្យរ៉ូស៊ីនឹងទៅថតទៅអីនឹងមើលចឹងទៅថាទឹកដក់ក្នុងកំរងទឹកនោមទឹកដក់ក្នុងកំរងទឹកនោមផងហើយនឹងក្រពះផងហើយពោះវៀនផង។

ក៖ អីច្រើនមុន?

ខ៖
អីផុតពីរនឹងទៅពេទ្យនឹងអោយតបៗអីក៏មិនហានស៊ីៗស៊ីតែបាយសោនយូរៗឡើងទៅអស់រលិងឡើងទៅឈាមក្រហម។

ក៖ អរ!

ខ៖
ឡើងឈាមសរបូមឈាមនឹងមីប្អូននឹងផងអាប្អូនណានោះពីរបីនាក់បូងដាក់តៗពីរប្អូនប្រាំនាក់។

ក៖ ដល់កាពិតឈាមសរស៊ីឈាមក្រហមសោះ?

ខ៖
អីឈាមសរស៊ីឈាមក្រហមសោះពេទ្យគេនឹងបានទៅក្រលុងឈាមទៅក្រលុកឈាមហើយអាណាទៅក្រលុកឈាមនៅនឹងម៉ាស៊ីនហើយក៏ម្លាំងវានឹងម៉ាទិកៗចឹង។

ក៖ ក្រលុកឈាមនឹងធ្វើឡើងដើម្បី?

ខ៖ មិនដឹង។

ក៖ ចេះតែនឹកឃើញតែម្តង?

ខ៖  នឹងហើយពេទ្យគេអោយយើងនឹងទៅក្រលុកឈាម។

ក៖  ចាំ!ៗ

ខ៖
ខ្ញុំនឹងមិនហានយកកូនខ្ញុំនឹងទៅក្រលុកអីបើលកូនខ្ញុំនឹងវានឹងឈឺហើយថាមិចក៏មិនទៅចុះយកទៅអោយតស្ងៃទៅក្នុងម៉ាស៊ីននឹងអាមិចទៀតទេ។

ក៖  ចាំៗចឹងម៉ាក់យាយតាំងពីរហូតដល់សព្វថ្ងៃនឹងចូលចិត្តហូបម្ហូបអីជាងគេដែល?

ខ៖  បើខ្ញុំនិយាយហូបម្ហូបនឹងមានអីមានតែត្រីអាំងសម្លម្ជូរងានឹងចូលចិត្តជាប្រចាំម៉ង។

ក៖  នឹងចូលចិត្តតែម្តង?

ខ៖  នឹងប្រចាំតែម្តងហើយប្រហុកជញ្ជាំហើយបើមិនជញ្ជាំដាក់ទាំងមូល។

ក៖  ចំហុយទាំងមូលទៅ?

ខ៖
ចាំចំហុយទាំងមូលជូនការមានអីច្រលូកចឹងទៅបើមិនមានច្រលូតចង្អុលដៃលៀកនឹងមេដៃនឹងហើយ។

ក៖
ចាំនឹងជាជីវិត្តដែលម៉ាក់យាយនឹងហូបរាល់ថ្ងៃចុះកាលនៅពីក្មេងៗចូលចិត្តលេងល្បែងប្រជាប្រិយភាពដូចជាប៉ោះឈូង ឬក៏ចោលអង្គុញអីនឹងម៉ាក់យាយ?

ខ៖
កាលពីមុនមកខ្ញុំនឹងធ្លាប់លេងប៉ោះឈូងចោលអង្គុញលេងចឹងទៅខ្ញុំនឹងបានហាត់សិល្បះចឹងទៅកាលសិល្បះជំនាន់អាពតមុនខ្ញុំនឹងរៀបការជំនាន់អាពតនឹង។

ក៖  គេនឹងបានហាត់សិល្បះផ្នែកអីគេ?

ខ៖  ហាត់សិល្បះខាងរបាំង។

ក៖  របាំងអក្សរ៉ាប្បមួយក៏ម៉ាក់យាយរាំរបាំងជូនពរ?

ខ៖  ខាងរបាំងជូនពរចាក់ល្មោចឹងណា។

ក៖  ចា៎ៗជំនាន់នឹងគេនឹងមានការរីកហាត់ចឹងដែល?

ខ៖
មានកើតឡើងទៅគេអោយទៅបានច្រៀងអាយ៉ៃអីទៅបានប្រលងអាយ៉ៃប្រលងពីនឹងគេទៅដែលនឹង។

ក៖  អត់ខ្លាចគេនឹងយកទៅសំម្លាប់ទេការនឹង?

ខ៖  អាណាគេដឹងទៅបើគេអោយទៅណាទៅនឹងទៅគេ។

ក៖  ចា៎!

ខ៖  អាណាដឹងគេសំម្លាប់មិនសម្លាប់បើមិនដឹងផងនឹង។

ក៖ បើប៉ុន្តែបើគេនឹងអោយយើងនឹងធ្វើអីយើងធ្វើនឹងទៅតាមគេទៅ?

ខ៖  ធ្វើតាមគេបើយើងនឹងមិនធ្វើតាមគេ។

ក៖  ដឹងខ្លាចគេសំម្លាប់ទៀត?

ខ៖  បើមិនធ្វើតាមគេខ្លាចគេសំម្លាប់នឹងគេដាក់ទារុញកម្មទៀត។

ក៖  ជាមូលហេតុធ្វើតាមគេនឹង?

ខ៖  នឹងហើយ។

ក៖
ចឹងអើយតើម៉ាក់យាយចេះចំរៀងអីខ្លះដែលម៉ាក់យាយចូលចិត្តច្រៀងតាំងពីរតូចរហូតដល់ធំទេ?

ខ៖  ចេះអត់ឯងអើយចេះប៉ុន្តែឥឡូវនឹងភ្លេចបាត់អស់ហើយមិនបានចាំទេ។

ក៖  អត់បានចាំទេ?

ខ៖
មិនបានចាំទេវីរីកគិតតែពីរឿងកូននឹងឈឺគិតពីរឿងកូនចៅនែ៎កូនកំព្រាកូនចៅរៀននែ៎។

ក៖ ចា៎!

ខ៖
រៀនម៉ារព្រឹកអស់បីបួនប្រាំពាន់ទៅរកលុយនៅឯណាម៉ែវាដើរបេះប៉ោះនេះចិញ្ចឹមទឹកដោះគូរពីតូចនឹងមិនបានអីនោះម៉ែវាទេ។

ក៖ ចា៎!

ខ៖
ដើរបួតត្រួយអំពិលនឹងមុខផ្ទះទេនឹងតាមមុខផ្ទះគេនឹងយកមកតាមផ្លូវយើងទេណាផ្លូវនឹងនេះគេនឹងស្ដីអោយទៀតគេនឹងជាអើយដើរបេះដើរប៉ោះដើរលក់ថាខ្លួនឯងនឹងដើរលក់លក់ដើម្បីសន្សំតិញលុយទិញទឹកដោះគូរអោយមីនៀប។

ក៖ ចា៎!

ខ៖ អោយចៅផង។

ក៖ ចិញ្ចឹមគ្រួសារផង?

ខ៖ នឹងហើយ។

ក៖ ចា៎!

ខ៖ ណាទៅមើលម៉ែវានឹងផង។

ក៖
ចា៎ចឹងតើម៉ាក់យាយអាចប្រាប់ខ្ញុំបានទេនៅក្នុងគ្រួសាររបស់ម៉ាក់យាយតើមាននរណាចេះលេងភ្លេងឧបករណ៍ជា រនៀត ជីតា ចាប៉ី ទ្រ ទេ?

ខ៖ អត់មានទេ។

ក៖ ហើយដូចជាចៅក្រោយអោយគាត់តាំងចិត្តអោយនឹងរៀនសិល្បះទេ?

ខ៖  ទេខ្ញុំបើថាបើមីមួយនេះចូលចិត្តចង់អោយរៀនសិល្បះទៀត។

ក៖ ចាំ!

ខ៖
ពីព្រោះវានឹងពិនរាំដែលយើងនឹងអត់មានមុខជំនៀនអោយវានឹងមានអ្នកដែលដូចជាបង់គោណាឯងចុះអត់បង់គោមានអ្នកណានៅក្នុងសិល្បះចឹងទៅមើលគេនឹងដឹងនាំទៅរៀនចឹងទៅយើងនឹងអត់មានអ្នកណាគោលអត់មានអ្នកណាជាសាច់មានអីចឹង។

ក៖ ចាំ!ចឹងក៏អត់ទៅ?

ខ៖  ដឹងធ្វើមិចកំពុងអោយចូលនៅរឿងតើ។

ក៖
អោយគាត់នឹងចូលនៅក្នុងខាងផ្នែតសិល្បះខាងអង្គការចឹងតើផ្ទះម៉ាក់យាយរស់នៅឪពុកម្តាយតាំងពីរតូចដល់ធំផ្ទះនឹងមិចដែលម៉ាក់យាយ?

ខ៖  ផ្ទះស្លឹក។

ក៖ ផ្ទះស្លឹក?

ខ៖  ផ្ទះស្លឹកផ្ទះអាស្បីរ៉ៃព្រគៀងស្លឹក។

ក៖ ដំបូលនឹងធ្វើអំពីស្លឹក?

ខ៖  ធ្វើស្លឹកដែលនឹង។

ក៖ អានៀបអាស្បី?

ខ៖  អានៀបស្បីហើយជញ្ជែងនឹងដេរស្លឹកក្រង់ធ្វើក្រជបចឹងទៅគ្រឿងអាស្បីនឹង។

ក៖ ដាក់ជ្រុងចឹងទៅ?

ខ៖ នឹងហើយ។

ក៖ ចាំចឹងគេហៅជញ្ជែងគ្រឿងអាស្បីរ៉ៃមួយផ្ទាំងដាក់មួយផ្ទាំង?

ខ៖  វ៉ៃមួយផ្ទាំងលើកដាក់មួយផ្ទាំងចឹងទៅ។

ក៖
ចាំចឹងតើម៉ាក់យាយគេការនឹងសង់ខ្លួនឯងឬមួយក៏ជីតាឪពុកម្ដាយជួលគេនឹងអោយសង់?

ខ៖  អឺ!កាលនឹងឪពុកខ្ញុំនឹងជួលគេធ្វើ។

ក៖  ចឹងម៉ាក់យាយជួរគេធ្វើ?

ខ៖  មិនបានជួរគេទេរកគេ។

ក៖  ចឹងកាលនឹងគាត់អត់ចេះធ្វើចឹងកាលនឹងគេបានហៅថាក្រប៉េះដៃគ្នាធ្វើ?

ខ៖
កាលនឹងខ្ញុំនឹងប្រប៉េះដៃគ្នានឹងធ្វើការនឹងជួយគ្នាទៅវិញទៅមកធ្វើតែដើមឈើកាលនឹងច្រើនឈើដែលដុះក្នុងស្រែកាលនឹងជាដើមល្បែងជាដើមក្រចេះដើមអីនឹងដើមស្ដៅ។

ក៖  ចាំ!

ខ៖  គាត់នឹងធ្វើនឹងដើមត្នោត។

ក៖
ចាំចឹងតើម៉ាក់យាយអាចប្រាប់ខ្ញុំបានទេថាកាលនឹងមានសំភារៈដូចជាសម័យយើងឥឡូវនឹងមានអាណារអាអូដូចជាមានម៉ាទ័រកាត់កាត់ឈើអីដែលកាលនឹង?

ខ៖
មិនទេមានតែអាណារអត់មានអាណារអាធំដាក់លែងជីតធ្វើរាជាកង់ចឹងៗវ៉ែងនឹងចឹងទៅណាអាវ៉ែងអាណារគេនឹង។

ក៖  អាណារអាដៃចឹងការនឹង?

ខ៖  នឹងហើយអាណារអាដៃគេនឹងបានឈរអាចឹង។

ក៖  អាណារអាដៃហើយជំនាន់នឹងមានដែកគោដែល?

ខ៖  មានពូថៅមានដែលដែកគោលមានដែលឈូក។

ក៖ អូចឹងជំនាន់នឹងមានទៀតអស់តែលើកលែងតែជំនាន់នឹងអាទ័រអីនឹងអត់មាន?

ខ៖ នឹងលើកលែងអាណាអរអីដែលអាទ័រអីគេអីគេអា។

ក៖ ស្វានអីនឹង?

ខ៖ ស្វានអីនឹងអត់មានអីទេ។

ក៖ ខ្ញុំស្មានតែមានតាំងពីជំនាន់នឹងដែល?

ខ៖ អត់មានទេៗមានតែអោយនេះនឹង។

ក៖
ចាំចឹងតើម៉ាកយាយអាចប្រាប់ខ្ញុំបានទេថាម៉ាកយាយបានចេះជំនៀងអីខ្លះពីក្រុមគ្រួសារដូចជាកាលដេរជំត្បាញធ្វើក្រមាកន្ទេឬមួយក៏ធ្វើតុទូធ្វើអំពីផ្តៅឬមួយក័កូស្គរត្នោតអីនឹងចេះទេម៉ាកយាយ?

ខ៖
ចេះកូស្គរត្នោតនឹងចេះធ្វើកន្ទេស្លឹកត្នោតនឹងខ្ញុំចេះធ្វើស្មុកនឹងខ្ញុំចេះស្បោនឹងក៏ខ្ញុំនឹងចេះ។

ក៖ ធ្វើកន្ទេស្លឹកត្នោតនឹងម៉ាកយាយនឹងបានធ្វើនឹងទុកហាស្រូវនឹងខ្លួនឯង?

ខ៖ ទុកហាស្រូវនឹងខ្លួនឯង។

ក៖ មានធ្វើដើម្បីទុកលក់ទេ?

ខ៖
អត់មានធ្វើអែ!មានធ្វើលក់ដែលលក់កាលម៉ារជំនាន់នឹងយើងនឹងងបានធ្វើយើងបែកចេញមកយើងនឹងអត់មេយវានឹងរាំងនឹង។

ក៖ ចាំ!

ខ៖
កាត់ធ្វើស្លឹកកន្ទេស្លឹកត្នោតនឹងលក់ដូរពូតចឹងដែលលក់ដូរពូតដូរយកអង្ករគេនឹងចឹងដែលចុះមេយយើងនឹងបានរាំងនឹងធ្វើស្រូវនឹងមិនបានតើកនែំ។

កៈ
ចឹងកាលនឹងម៉ាកយាយអើយបានធ្វើកន្ទេលក់នឹងម្តងៗបានប៉ុន្មានកាសទៅម៉ាកយាយមួយហាសិមបាតមួយហាសិមរៀលអីទេ?

ខៈ ដូចជាមិនដែលនឹងបានស្គាល់បានចោលលុយចោល ចោលតែស្រូវអង្ករដូរពូត។

កៈ ចាំដូរបានតែពីងនឹង?

ខៈ នឹងហើយ!

កៈ
បញ្ហានៅក្នុងជីវិតរបស់ម៉ាកយាយអាចប្រាប់ខ្ញុំបានទេមានការពិបាកជួនជត់អីខ្លះនៅក្នុងជីវិតមានសាច់រឿងអ្វីមួយដែលបានចង់ចាំមិនអាចនឹងបំភ្លេចបានមានទេម៉ាកយាយ?

ខៈ
បញ្ហាដែលខ្ញុំមិនអាចនឹងបំភ្លេចបានមានតែការនឿយហាត់រាល់ថ្ងៃនឹងដែលមានពេលស្រនុកទេខ្ញុំចង់ចាំថាខ្ញុំនឹងមិនដែលនឹងឆ្នាំណាខែណាថ្ងៃណាដែលខ្ញុំនឹងបានស្រនុកទេឬមួយទាល់តែខ្ញុំនឹងផុតរលុតទៅក៏មិនបានដឹងបានខ្ញុំនឹងបានស្រួយខ្ញុំនឹងនៅក្នុងព្រះធនីនឹងព្រះអាគីនឹងក៏មិនបានដឹង។

កៈ
ចេះតែមានម៉ាកយាយអត់ដឹងថាពេលដែលបានស្លាប់ទៅខាងព្រលឹងវិញ្ញាណគេនឹងមិនបានយកទៅធ្វើអីផងនឹងចឹងម៉ាកយាយនឹងគិតអីចឹង?

ខៈ
ពោះចឹងរស់យើងនឹងមិនបានឃើញមិនបានដឹងគេនឹងបានយកយើងទៅនឹងចុះគេណាយើងនឹងបានបើមិនដែលមានពេលស្រនុកឯងណាសួរមើលដូរអ្នកជិតខាងនឹងមើល៕

កៈ
ទិចទៀតពេលដែលចៅៗម៉ាកយាយនឹងគាត់នឹងធំៗទៅបានសងគុណនឹងការដែលគាត់នឹងបានទង្វើដែលម៉ាកយាយនឹងបានចិញ្ចឹមបីបាច់ពួកគាត់ណា?

ខៈ អើយសាធុៗអោយបានដូចចឹងទៅ។

កៈ
ចាំកុំអាលអោយអស់សង្ឃឹមជឿខ្ញុំទៅនឹងហើយចឹងតើម៉ាកយាយមានពេលណាដែលបាន
សប្បាយចត្តិខ្លះទេរាល់ថ្ងៃនឹង?

ខៈ
ទេមានពេលសប្បាយចិត្តខ្លះចឹងដែលដូចថាយើងនឹងបានគិតចឹងទៅកូនៗគេនឹងបាននាំគ្នា
នឹងលេងអីចឹងទៅក៏សើចសប្បាយចឹងនឹងគេនឹងដេលនឹង។

កៈ ចាំភាពអុនអរនឹងគេដែលចឹងនឹងគេនឹងឯងចឹងទៅ?

ខៈ ចាំ!

កៈ
ចឹងអើយតើចំពោះម៉ាកយាយផ្ទាល់តើម៉ាកយាយធ្លាក់មានបំណងប្រាថ្នានៅក្នុងជីវិតរបស់
ម៉ាកយាយនឹងដូចថាបំណងតាំងពីតូចរហូតដល់សព្វថ្ងៃនឹងដល់ធំនឹងបំណងប្រាថ្នាបើបាន
ក្លាយជាគ្រូចង់រៀនក័ចង់រៀនពេទ្យឬក៏អ្នកសិល្បៈអីយ៉ាងដែលម៉ាកយាយធ្លាក់មានបំណង
ពងប្រាថ្នាធ្លាក់មានទេ?

ខៈ
ខ្ញុំវាដល់មលដល់បច្ចុប្បន្នឥឡូវនឹងខ្ញុំនឹងបានចង់ប្រាថ្នាអោយតែកូនចៅខ្ញុំទេនឹងអោយកូន
អើយខំព្រឹងរៀនសូត្រទៅក្រលែងល្អបានធ្វើជាគ្រូធ្វើជាពេទ្យអីនឹងគេទៅម៉ែឪនឹងបានធូរធា
នឹងគេទិចកុះអោយវានឹងបានអស់សង្ឃឹមនឹងគេឈឺអីទិចទួចនឹងកុំអោយរត់ទៅរកនឹងគេ
ឈឺអីទិចទួចនឹងរត់ទៅរកគេគ្រាន់តែខ្ញុំនឹងមានសង្ឃឹមនឹងកំរងនឹងនិយាយទេតែកូនមិនបា
នពេលណានឹងបានព្រឹតអររៀននឹងមិនបានទាន់នឹងប៉ុន្មានផងអើយម៉ែឪនឹងបានពិបាកពេ
ករត់ទៅធ្វើការនឹងអស់ហើយអាយុ១១ ១២
១៣នឹងបានទៅធ្វើការនឹងអស់ហើយពេញនឹងអស់ហើយ។

កៈ ចាំ!
ចឹងអើយជាចុងក្រោយតើម៉ាកយាយមានអីនឹងបានផ្តាំផ្ញើរដល់កូនចៅជំនាន់ក្រោមនឹងតើ
អោយគេនឹងបានខំប្រឹងរៀនសូត្រអីខ្លះតើមានទេម៉ាកយាយ?

ខៈ សូមផ្តាំផ្ញើរម៉ារជំនាន់ក្រោមនឹងសូមអោយតែកូនខំប្រឹងរៀនប្រឹងសូត្រចាំ។

កៈ ចាំ!

ខៈ បឹងនឹងអោយបានធ្វើការធំនឹងគេទៅ។

កៈ ចាំ!ចឹងម៉ាកយាយ?

ខៈ កុំអោយនឹងពិបាកវេនាដូររូបខ្ញុំនឹងពេក។

កៈ ចាំដូចជា!

ខៈ អោយបានចេះដឹងទៅ។

កៈ
គ្រាន់ការមានការងារអ្វីមួយនឹងដែលគាត់មាននឹងដូចជាអាជីវអ្វីមួយនឹងឬមួយក៏គាត់នឹងបានចាប់អាជីវផ្ទាល់ខ្លួននឹងណាសូមព្យាយាមអោយគាត់នឹងសូមព្យាយាមចាប់អាជីវនឹងទុកអាណាគតគាត់នឹងអោយជាក់លាក់នៅក្នុងជីវិតចង់ណាម៉ាកយាយហើយបើអោយគាត់នឹងបានជៀបរៀងអ្វីខ្លះនៅក្នុងជីវិតរបស់គេម៉ាកយាយ?

ខៈ
ខ្ញុំបើអោយដឹងនាំកូនចៅខ្ញុំនឹងជៀបរៀងថាគ្រឿងញៀងមួយគឺជាផ្លូវមួយដែលគេនឹងមិនអោយផ្លូវដើរកូនកុំប្រឹងប្រព្រឹត្តិតែពឹងនឹងតែបើកុំម្លោំងកូនដែលបានខំប្រឹងរកស៊ីសុចរិខ្លួនឯងបេះប៉ោះបានក៏បានទៅមិនបានក៏ហីទៅ។

កៈ ចាំ

ខៈ សូមអោយជៀបរៀងតែគ្រឿងញៀងមួយនឹង។

កៈ ចាំ!ចឹងអស់ហើយម៉ាកយាយ?

ខៈ
នឹងហើយដែលរបស់រកបបរដែលគេនឹងមិនបានអោយយើងនឹងបានដើរកុំអោយយើងនឹងបានប្រព្រឹត្តិកុំប្រព្រឹត្តិ។

កៈ ចាំ!

ខៈ ពោះរបស់នេះវាមិនបានស្របច្បាស់។

កៈ ចាំ!

ខៈ  ពឹងនឹងឯង។

កៈ ចាំ!ចឹងអើយម៉ាកយាយមានតែពឹងនឹង នែ៎ម៉ាកយាយនែ៎?

ខៈ  ចាំ!

កៈ ដែលបានផ្ញើរកូនចៅជំនាន់ក្រោយនឹងណាម៉ាកយាយ?

ខៈ  ចាំ!

កៈ
ចឹងជាចុងក្រោយខ្ញុំសូមអរគុណម៉ាកយាយដែលបានចំណាយពេលដល់មានដំម្លៃមកកាត់សាលារៀនb y u
របស់ពួកខ្ញុំនឹងអាមេរិចនឹងហើយខ្ញុំសង្ឃឹមថាអ្វីទាំងអស់នឹងដែលម៉ាកយាយបានប្រាប់ពីខ្សែរជីវិតរបស់ម៉ាកយាយនឹងណាទៅកាត់ក្មេងជំនាន់ក្រោយហើយអោយបានការរៀបរៀងគ្រឿងញៀងឬមួយក៏សូមអោយគេនឹងមានជីវិតនឹងពួកគេនឹងមានជីវិតនឹងដល់ល្អប្រសើរអោយគេនឹងបានប្រកបមុនរបអីអ្វីមួយចឹងណា?

ខៈ  អ្វីមួយសូមអោយគេនឹងបានដើរទៅតាមផ្លូវទៅតាមច្បាស់ទេ។

កៈ ចាំ

ខៈ
កុំអោយតែដើរនឹងខុសច្បាស់នឹងអារឿងគ្រឿងញៀននឹងគេមិនបានអាយើងបឹងប្រព្រឹត្តិនឹងយើងនឹងកុំប្រព្រឹត្តិ។

កៈ ចាំៗ

ខៈ  តែពឹងនឹងឯង។

កៈ
ចឹងខ្ញុំសុំជូនពរឆ្នាំថ្មីសូមអោយម៉ាកយាយការរកស៊ីទទួលទានមានបានរិចចំរើនពីមួយថ្ងៃទៅមួយថ្ងៃជារាល់រហូតណាម៉ាកយាយណាម៉ាកយាយណា?

ខ៖ សាធុរ!!

ក៖ ជាពិសេសក្រុមគ្រួសារទាំងអស់សូមអោយមានសុភមង្គលនឹងការធ្វើដំណើរទៅណាមកណាពរពេញទៅដោយសុវត្ថិភាពទាំងអស់ណាម៉ាកយាយណា?

ខ៖ សារធូរសូមផ្ដាំផ្ញើរទៅដល់អាមេរិចផងអោយលោកជួយខ្ញុំផងកូនចៅនឹងច្រើន។

ក៖ ចាំចឹងខ្ញុំអរគុណម៉ាកយាយ?

ជីវប្រវត្តិសង្ខេបរបស់អ្នកមីង អែន លី

ក៖ គាត់ជាមនុស្សដែលពិបាកណាស់ហើយគាត់នឹងបានខំចិញ្ចឹមកូនចៅគាត់នឹងបានដោយលំបាកហើយគាត់នឹងបានព្យាយាមនៅក្នុងជិវិតគាត់នឹងខ្លាងហើយគាត់នឹងមិនបាននឹងសប្បាយចត្តិនឹងគេទេមកពីជីវភាពគាតើនឹងមិនបានល្អនឹងគេហើយគាត់នឹងបានដើរលក់បន្លែទិចបង់ទូចនឹងមកចិញ្ចឹមកូនចៅគាត់តាំងពីរតូចមកគាត់ជាមនុស្សដែលបានតស៊ូរនៅក្នុងជីវិតគាត់ខ្លាងណាស់។